**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:០៥
ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦
**សាលដីកា**
លេខ:៤១
ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............ ជាចៅក្រម
៥-លោក ............ ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

-លោក ..............

**តំណាងមហាអយ្យការ**

-ឯកឧត្តម ............ ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២៦"ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០០៥ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ០៥ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦ របស់តុលាការកំពូល ។

**ពីបទ:**យុបយិតគ្នាយកផ្ទះទៅលក់និង រំលោភកិច្ចការប្រញ្ញាប់ ។

-ជនត្រូវចោទឈ្មោះសស(ជាចុងបណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ របរកស៊ីចៅ សង្កាត់ទីលំនៅសព្វថ្ងៃផ្ទះលេខ៣៨៦ ក្រុមទី៨ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌទានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះសេង សុន"ស" ម្ដាយឈ្មោះ សេង ម៉ៅ"ស" ប្រពន្ធឈ្មោះហែម ស៊ីថានមានកូន០៣នាក់ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះសព(ជាម្ចាស់បណ្ដឹងសាទុក្ខ) ភេទស្រី អាយុ៦៧ឆ្នាំជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៨១E ផ្លូវរោងចក្រកែវសង្កាត់ស្ទឹ ងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-មានមេធាវី លោក ..............

តាមពាក្យបណ្ដឹង ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះសពប្ដឹងពីឈ្មោះសសឃុបឃិតគ្នាយកផ្ទះខ្លួនលក់ឱ្យអ្នកដទៃ ពេលដីកាសម្រេចកិច្ចការប្រញាប់កំពុងអនុវត្ត តុលាការក្រុងភ្នំពេញសម្រេចហាមឃាត់សាលាក្រុងមិនឲ្យលក់ ដូរ ដូល បញ្ចាំ ផ្ទេរសិទ្ធិ និងធ្វើអំណោយទៅអ្នកដទៃនូវផ្ទះលេខ៤១$E_0E_1$ទាំងមូល ស្ថិតនៅភូមិថ្មី ក្រុម៣ សង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ ទុកជាបណ្ដោះអាសន្នរងចាំ តុលាការសម្រេចដល់អង្គសេចក្ដី ។

-បានឃើញដីកាតម្កល់រឿងទុកឥត់ចាត់ការលេខ១០២៧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០២ របស់អយ្យការ អមតុលាការក្រុងភ្នំពេញ ដែលបានសម្រេច តម្កល់រឿងនេះទុកមិនចាត់ការតទៅ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះសព ដែលប្ដឹង មិនសុខចិត្តនឹងដីកាតម្កល់រឿងទុកឥតចាត់ការលេខ១០២៧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០២ របស់អយ្យការ អមតុលាការក្រុងភ្នំពេញ លើដីកាសម្រេចទាំងមូល ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យករ អមសាលាឧទ្ធរណ៍ថា ៖ គួរតម្កល់ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការទុកជាបានការដដែល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៦"ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច៖

១/-ទទួលបណ្ដឹងឧទ្ធរណ៍លេខ២១ ចុះថ្ងៃទី១៧-៥-២០០២ របស់ឈ្មោះសព ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ បដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចរឿងទុកឥតចាត់ការលេខ១០២៧ ចុះថ្ងៃទី០៣-៥-២០០២ របស់អយ្យការអមតុលាការក្រុងភ្នំពេញទុកជាជនការពេញទាំងមូល ។

៣-ដីកានេះមានអានុភាពអនុវត្តភ្លាមៗ ។

សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះសព ប្ដឹមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ២៦"ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ឈ្មោះសុខ ហៅ (ជាម្ចាស់បណ្ដឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៦ របស់ឈ្មោះសស(ជាចុងបណ្ដឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានស្ដាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យករ អមតុលាការកំពូលថាៈ រឿងនេះជារឿងរបស់សាលាក្រុងភ្នំពេញ មិនមែនជារឿងរបស់ចៅសង្កាត់ទេ ។ សូមតម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៦ "ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសព(ជាក្នុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា ឆ្នាំ១៩៧៩ លោកសសជួយរកម៉ូយឲ្យនាងខ្ញុំលក់ផ្ទះនាងខ្ញុំបាន៩០០០ (ប្រាំបួនពាន់ដុល្លា) ប្រាប់នាងខ្ញុំថា ដាក់ទីស្នាក់ការ ស្រាប់តែដាក់ឲ្យជាងថតរូបទៅវិញ បន្ទាប់មក ទៀតដាក់ឲ្យជួលលក់ទូរស័ព្ទដៃ ដល់នៅឆ្នាំ១៩៩៨ លោកសសបានឡើងជាប្រធានសង្កាត់ បន្ទាប់មកការទាមទារពីរឿងផ្ទះរបស់នាងខ្ញុំ មិនបានផលអ្វីសោះសម្រាប់នាងខ្ញុំ ។ ទើបនាងខ្ញុំមិនសុខចិត្ត ក៏បានប្តឹងលោកសសបានឃុបឃិតយកផ្ទះនាងខ្ញុំលក់ និងជួលដែលមានលេខ៤១$E_0$៤១$E_1$៤២$E_0$ ៤២$E_1$។ សំណូមពរ សូមយកផ្ទះនាងខ្ញុំទាំងអស់វិញ សូមឯកឧត្តមប្រធានជួយរកយុត្តិធម៌ឲ្យ នាងខ្ញុំផង ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះសសជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះថាៈ ខ្ញុំបាទពុំបានយកផ្ទះរបស់សព ទៅលក់អោយអ្នកដទៃដូចការលើកឡើងនៅក្នុង សារណារបស់ខ្លួននោះឡើយ ។ សព និយាយនេះមិនត្រឹមត្រូវទេ ព្រោះថា ឆ្នាំ១៩៩៨ ខ្ញុំបាទទើបឡើងធ្វើជាមេឃុំ និងការប្រគល់ផ្ទះទំនាស់ឱ្យទៅកងរាជអាវុធហត្ថនេះ គឺពុំពាក់ព័ន្ធនិងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្ញុំបាទឡើយ ។ សំណូមពរ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លក ............. ជាមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសព (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : រឿងនេះមិនទាន់ចប់ជាស្ថាពរព្រោះថា ជារឿងនៅក្តីក្តាំនៅឡើយ តាមពិតអ្នកនៅកាន់កាប់ផ្ទះរបស់អ្នកស្រីសព មាន៦គ្រួសារទៅហើយ មិនមានកងរាជអាវុធហត្ថអ្វីនោះទេ ព្រោះនថា លោកសសជាចៅសង្កាត់ត្រូវទទួលការដឹងលឺថា អ្នកណាចូលមកនៅតាមពិតគ្មានPMរឺកងរាជអាវុធហត្ថមកនៅដូចពាក្យលោកសសនោះនិយាយ ជាតុពិតមានតែឯកជនរស់នៅផ្ទះរបស់អ្នកសព តែប៉ុណ្ណោះ ។

ឯកឧត្តមហង្សរ៉ូ រ៉ាគេន ក៏ពិនិត្យរួចហើយដែរ ចំណែកតុលាការក្រុងភ្នំពេញក៏ដូចសាលាឧទ្ធរណ៍មិនបានពិនិត្យត្រឹមត្រូវឡើយ វាជាកំហុសធ្ងន់ធ្ងរណាស់ចំពោះរឿងនេះ ។ សំណូមពរ ចៅក្រមស៊ើបអង្កេតគប្បីស៊ើបឡើងវិញឲ្យបានត្រឹមត្រូវ សូមឯកឧត្តមប្រធាន មេត្តាបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីស៊ើបអង្កេតឡើងវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថាៈ រឿងនេះគឺជារឿងពាក់ព័ន្ធការទិញលក់ផ្ទះ មិនមានការពាក់ព័ន្ធរឿងព្រហ្មទណ្ឌទេ គឺជារឿងរដ្ឋប្បវេណីតែជនរងគ្រោះប្តឹងចៅសង្កាត់ជារឿងព្រហ្មទណ្ឌ គួរពិចារណា ព្រោះបុគ្គលដែលត្រូវគេប្តឹង នៃអាចមានកំហុសក្នុងរឿងព្រហ្មទណ្ឌឡើយហើយក៏មិនមានភស្តុតាងណាជាលាយល័ក្ខអក្សរដែរសូមតម្កល់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រីសព និងចម្លើយរបស់ជនជាប់ចោទឈ្មោះសសសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី .
-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ របស់អ្នកស្រីសព ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។
-យល់ឃើញថា ផ្ទះដែលជាកម្មវត្ថុនៃការប្តឹងចោទប្រកាន់នេះត្រូវបានអាជ្ញាធរក្រុងភ្នំពេញ តាមសេចក្តីសម្រេចលេខ៣៧៤ សល ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៤ ប្រគល់ឲ្យទៅកងរាជអាវុធហត្ថប្រចាំ រាជធានីភ្នំពេញរួចហើយ ដូច្នេះការចាត់ចែងរឿងផ្ទះនេះ ត្រូវផុតពីសមត្ថកិច្ចរបស់លោកសសដែលជាចៅសង្កាត់ទៅហើយ ។
-យល់ឃើញថា ការដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា លោកសសត្រូវ ទទួលខុសត្រូវចំពោះការចូលមកស្នាក់នៅរបស់ប្រជាជនផ្សេងទៀតនោះ បើរឿងមានពិតមែននោះវាជា រឿងរដ្ឋបាល ពុំមែនជាបទអាជ្ញាទេ ពីព្រោះពុំមានភស្តុតាងណាបញ្ជាក់ថា លោកសសរួមគំនិតក្នុង
ការចាត់ចែងផ្ទះ ដែលតុលាការបានហាមឃាត់នេះទេ ។
-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២៦(ខ) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

១-ទទួលបណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ របស់អ្នកស្រីសពទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។
២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៦(ខ) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលា-ឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។
៣-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ។